**ធម្មទេសនារបស់លោកអភិបាល អូលីវីយេ**

**អភិបូជាបុណ្យឆ្លងឆ្នាំនៅព្រះសហាគមន៍សន្តីម៉ារីញញឹម**

**ចំការខៀវ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

# ឆ្នាំថ្មីឲ្យយើងចេះស្រឡាញ់និងបម្រើ

**អត្ថបទទី១៖ យ៉ូហានទី១ ២,១៨-២១**

រីឯអ្នករាល់គ្នាវិញ ព្រះដ៏វិសុទ្ធបានចាក់ប្រេងយមកលើអ្នករាល់គ្នា ហើយអ្នកក៏បានចេះដឹងទាំងអស់គ្នា។ ១យហ ២,២០

**ដំណឹងល្អ៖ យ៉ូហាន ១,១-១៨**

ព្រះបន្ទូលជាប្រភពនៃជីវិត ហើយជីវិតនោះជាពន្លឺបំភ្លឺមនុស្សលោក។ យហ ១,៥

បងប្អូនជាទីស្រឡាញ់!

អត្ថបទដែលយើងបានស្តាប់ មានព្រះនាងម៉ារីម្ខាង មានគ្រូគង្វាលម្ខាងទៀត ពេលគ្រូគង្វាលទៅថ្វាយបង្គំព្រះយេស៊ូគេបានរត់ ដើម្បីចែករំលែកអំណរសប្បាយដល់ប្រជាជនទាំងអស់ ដោយសារគេពោរពេញដោយសេចក្តីសុខថ្មី ពោរពេញដោយសេចក្តីសង្ឃឹមថ្មី គេមិនអាចទុកដំណឹងល្អដ៏អស្ចារ្យនេះសម្រាប់គេផ្ទាល់ទេ។ គេបានរត់ទៅប្រាប់ប្រជាជនទាំងឡាយ ឲ្យប្រជាជនទាំងអស់បានស្តាប់អំពីដំណឹងល្អនេះ យប់នេះមានព្រះសង្គ្រោះដែលបានប្រសូតហើយ។ ព្រះនាងម៉ារី នៅពេលឃើញព្រះយេស៊ូដែលប្រសូតហើយ មានគ្រូគង្វាល មានហោរាចារ្យ មានទេវទូត មានប្រជាជនដែលមកថ្វាយបង្គំ ណែនាំឲ្យព្រះនាងម៉ារីទុកអ្វីៗទាំងអស់នៅក្នុងដួងចិត្តរបស់គាត់ ដើម្បីអរព្រះគុណព្រះជាម្ចាស់នៅក្នុងរបៀបស្ងៀមស្ងាត់។ អ្វីដែលគាត់មើលឃើញ ជាទ្រព្យសម្បត្តិមួយយ៉ាងពិសេស ដែលព្រះនាងម៉ារីទុកថែរក្សានៅក្នុងដួងចិត្ត។

សម្រាប់យើងក៏ដូចគ្នាដែរ ទុកអ្វីៗទាំងអស់ដែលយើងបានឃើញពេញមួយឆ្នាំកន្លងមក ដើម្បីថែរក្សាអនុស្សាវរីយ៍ល្អៗ ដើម្បីជម្រះអ្វីដែលមិនល្អនៅក្នុងជីវិតរបស់យើង។ ដូចគ្រូគង្វាលនៅក្នុងឆ្នាំថ្មីនេះឲ្យយើងពោរពេញដោយកម្លាំង ដើម្បីបន្តបេសកកម្មរបស់យើងជាគ្រីស្តបរិស័ទ។ យើងមិនមែនជាគ្រីស្តបរិស័ទ ដែលមិនចេះចែករំលែកអំណរសប្បាយនៃបុណ្យព្រះយេស៊ូប្រសូត អ្វីដែលយើងបានមើលឃើញ អ្វីដែលយើងបានឮយើងត្រូវតែចែករំលែកជាមួយបងប្អូនឯទៀតៗ។ បន្តិចទៀត យើងចូលនៅក្នុងឆ្នាំ២០២០ណែនាំឲ្យយើងនឹកឃើញ១០ឆ្នាំកន្លងមក ពិភពលោកយើងបានរីកចម្រើនលឿនណាស់ នៅក្នុងរបៀបដែលយើងបង្កើតទំនាក់ទំនងតាមបណ្តាញទំនាក់ទំនងសង្គមថ្មីៗ។ ណែនាំឲ្យពិភពរបស់យើងបច្ចុប្បន្ននេះតូចណាស់ យើងដឹងទាំងអស់អ្វីដែលបានកើតឡើងនៅទីណា ពេលណា យើងស្គាល់គ្នាយ៉ាងច្រើននៅក្នុងពិភពលោក។ ប៉ុន្តែនៅក្នុង១០ឆ្នាំកន្លងមក ពិភពលោកយើងមានសង្គ្រាមច្រើនណាស់ណែនាំឲ្យពិភពលោករបស់

យើងកំពុងភ័យខ្លាចដែរ ទោះបីយើងបង្កើតទំនាក់ទំនងយ៉ាងស្រួលប៉ុន្តែការភ័យខ្លាចមានច្រើនជាងមុន ដោយសារមានមនុស្សមួយចំនួនចេះតែបង្កើតអំពើហិង្សា ការស្អប់គ្នា ច្រណែនគ្នា។ នៅប្រទេសកម្ពុជាយើងក្នុង១០ឆ្នាំកន្លងមក ក៏បានរីកចម្រើនដែរយើងមានភ្លើងអគ្គិសនីប្រើប្រាស់ យើងមានអាគារខ្ពស់ៗ ហើយបានចេញពីប្រទេសក្រីក្រទៀត។

ព្រះសហគមន៍របស់យើងនៅខេត្តតាកែវ ១០ឆ្នាំកន្លងមកយើងបានសាងសង់វិទ្យាស្ថានសន្តប៉ូល យើងបានសាងសង់សាលាមត្តេយ្យម៉ុនតេសូរីថ្មី យើងបានបង្កើតភូមិសុខសាន្ត យើងបានបង្កើតភូមិសិប្បកម្ម យើងបានបង្កើតមហោរស្រេព យើងបានបង្កើតសាលាបឋមសិក្សា យើងបានបង្កើតក្រុមសិល្បៈ យើងបានបង្កើតសាលាបច្ចេកទេស...។ យើងបានបង្កើតច្រើនណាស់ ម្នាក់ៗយើងអាចមើលផ្ទាល់ខ្លួនអ្វីដែលបានកើតឡើងនៅក្នុងរយៈពេល១០ឆ្នាំកន្លងមកនេះ។ ដូច្នេះ ១០ឆ្នាំខាងមុខ យើងធ្វើអ្វីខ្លះ អាទិភាពទីមួយឲ្យយើងគិតពិចារណា **តើខ្ញុំធ្វើដូចម្តេចដើម្បីទៅជាមនុស្សម្នាក់ដែលទទួលខុសត្រូវយ៉ាងច្បាស់លាស់ នៅក្នុងជីវិតខ្ញុំផ្ទាល់ នៅក្នុងព្រះសហគមន៍ និងនៅក្នុងសង្គម?** នេះជាអ្វីដែលសំខាន់បំផុតឲ្យយើងមានប្រជាជន ឲ្យយើងមានគ្រីស្តបរិស័ទ ឲ្យយើងមានមនុស្សដែលចេះទទួលខុសត្រូវយ៉ាងច្បាស់លាស់។ សូមថែរក្សាការទទួលខុសត្រូវដើម្បីឲ្យយើងទៅជាមនុស្សដែលមានទស្សនៈឈ្លាសវៃក្នុងការកសាងជីវិតផ្ទាល់ខ្លួន។ ពេលជីវិតរបស់យើងទទួលសេចក្តីសុខ នាំឲ្យប្រទេសរបស់យើងទទួលសេចក្តីសុខដែរ។

មួយទៀត ឲ្យយើងយកចិត្តទុកដាក់រស់នៅនៅក្នុងរបៀបព្រះយេស៊ូ ដោយចេះស្រឡាញ់និងចេះបម្រើ ស្រឡាញ់និងបម្រើ ទៅជាអាទិភាពនៃជីវិតរបស់យើងជាគ្រីស្តបរិស័ទ។ សេចក្តីស្រឡាញ់ដែលយើងបានទទួលពីព្រះជាម្ចាស់ សេចក្តីស្រឡាញ់ដែលយើងបានឃើញជាក់ស្តែងនៅពេលព្រះយេស៊ូបានចាប់កំណើតជាមនុស្ស ណែនាំឲ្យយើងរស់នៅនៅក្នុងសេចក្តីស្រឡាញ់នេះ។ ព្រះយេស៊ូមានព្រះបន្ទូលថា "**នៅពេលយើងអញ្ជើញភ្ញៀវកុំអញ្ជើញតែមិត្តសម្លាញ់ ឬបងប្អូនដែលនឹងអញ្ជើញយើងនៅពេលក្រោយបាន ប៉ុន្តែសូមអញ្ជើញបងប្អូនដែលគ្មានសមត្ថភាពដើម្បីអញ្ជើញយើងវិញ**"។ ឲ្យយើងធ្វើជាអ្នកបម្រើ ដោយដឹងថាយើងបានធ្វើផ្ទុយនឹងគំនិតនៅក្នុងសង្គម ឲ្យព្រះសហគមន៍របស់យើងទៅជាសញ្ញាសម្គាល់នៅក្នុងរបៀបព្រះយេស៊ូ ដោយចេះស្រឡាញ់និងបម្រើ។

ចុងក្រោយ ឲ្យយើងយករបៀបព្រះនាងម៉ារីទុកនៅក្នុងចិត្ត ដោយផ្ញើទៅព្រះជាម្ចាស់តាមរយៈការអធិដ្ឋាន។ ប្រសិនបើ យើងចង់ជោគជ័យនៅក្នុងជីវិតរបស់យើង ឲ្យយើងមានភាពទទួលខុសត្រូវយ៉ាងច្បាស់លាស់ និងមានភាពស្មោះត្រង់ដោយមានចិត្តស្រឡាញ់និងបម្រើ។ អ្វីដែលកើតឡើងពីមួយថ្ងៃទៅមួយថ្ងៃ ឲ្យយើងទុកនៅក្នុងចិត្តហើយផ្ញើទៅព្រះជាម្ចាស់ ដើម្បីមើលរបៀបព្រះជាម្ចាស់ដែលស្រឡាញ់យើង មើលរបៀបព្រះជាម្ចាស់ដែលមានព្រះហឫទ័យស្មោះត្រង់នឹង

យើង ដើម្បីឲ្យយើងមានចិត្តស្មោះស្ម័គ្រចំពោះគ្នាទៅវិញទៅមក ទាំងនៅក្នុងព្រះសហគមន៍ ទាំងនៅក្នុងសង្គម។ សម្រាប់១០ឆ្នាំខាងមុខ ឲ្យយើងយកចិត្តទុកដាក់ធ្វើជាមនុស្សដែលមានការទទួលខុសត្រូវជាន់ខ្ពស់ ឲ្យយើងមានចិត្តស្រឡាញ់និងបម្រើពិតប្រាកដ និងឲ្យយើងទៅជាមនុស្សដែលចេះអធិដ្ឋានដើម្បីទទួលពន្លឺពីព្រះជាម្ចាស់។ សមត្ថភាពរបស់មនុស្សមិនស្មើគ្នាទេ មានខ្លះមានសមត្ថភាពខ្លាំង មានខ្លះមានសមត្ថភាពតិច ប៉ុន្តែអ្វីដែលសំខាន់ឲ្យយើងធ្វើអស់ពីសមត្ថភាពនៅក្នុងការងារ នៅក្នុងជីវិត នៅក្នុងតួនាទីរបស់ខ្លួន។

យើងអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គប្រទានព្រះពរដល់យើងនៅក្នុងឆ្នាំថ្មីនេះ ឲ្យឆ្នាំថ្មីនេះទៅជាឆ្នាំពិសេស ទៅជាឆ្នាំមេត្តាករុណារួមជាមួយព្រះជាម្ចាស់ដែលស្រឡាញ់យើងយ៉ាងខ្លាំង។ អាម៉ែន៕